# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ  សាសនា  ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# សកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋាន
# គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា  ប្រចាំឆ្នាំ  ២០០៦

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា( **គ.ទ.ក** ) ត្រូវបានបង្កើតឡើងសំរាប់គ្រប់គ្រងដំណើរការនៃការធានានិងលើកកំពស់គុណភាពអប់រំឧត្តមសិក្សានៅកម្ពុជា  ឱ្យមានប្រសិទ្ធិភាពខ្ពស់ស្របតាមស្តង់ដារអន្តរជាតិ ។ **គ.ទ.ក** មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិ ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការបំពេញបេសកកម្មនិងអនុវត្តរាល់ភារកិច្ចទាំងឡាយរបស់គណៈកម្មាធិការនេះ។  នៅក្នុងឆ្នាំ២០០៦កន្លងមក អគ្គលេខាធិការដ្ឋានបានបំពេញបេសកកម្មនិងអនុវត្តរាល់ភារកិច្ចរបស់ខ្លួនដូចខាងក្រោមៈ

## I-  លទ្ធផលការងារ

### ១-ការងាររៀបចំស្តង់ដារនិងការទទួលស្គាល់គុណភាពអប់រំ

### ក-ការចុះវាយតម្លៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

យោងតាមស្មារតីនៃព្រះរាជក្រឹត្យ លេខ ០៣០៣/១២៩/រកត ចុះថ្ងៃទី ៣១ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានគឺជាឆ្នាំទីមួយនៃការសិក្សាថ្នាក់បរិញ្ញាប័ត្ររបស់និស្សិត។  គ្រឹះស្ថានឧត្តមសិក្សាដែលដំណើរការឆ្នាំសិក្សាមូល ដ្ឋានអាចចេញវិញ្ញាបនប័ត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋានជូនដល់និស្សិត ដែលបានបញ្ចប់ការសិក្សាប្រកបដោយជោគជ័យ លុះត្រាតែមានការទទួលស្គាល់គុណភាពអប់រំលើដំណើរការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋានពី  គ.ទ.ក។  ការចុះវាយតម្លៃលើដំណើរការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដើម្បីផ្តល់ការទទួលស្គាល់គុណភាពអប់រំ  អគ្គលេខាធិការដ្ឋានបានអនុវត្តតាម  សេចក្តីណែនាំណែនាំស្តីពីដំណើរការថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ និង សេចក្តីណែនាំស្តីពីដំណើការវាយតំលៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់មន្ត្រីវាយតំលៃ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៥ ។

ដំណើរការនៃការវាយតំលៃថ្នាក់ ឆ្នាំសិក្សាមូលដ្ឋានមានបីតំណាក់កាល ដូចខាងក្រោមៈ

១- គ្រឹះស្ថានឧត្តមសិក្សាត្រូវដាក់ពាក្យស្នើសុំការវាយតំលៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមកអគ្គលេខាធិការដ្ឋាននៃ គ.ទ.ក  ដើម្បីទទួលសិទ្ធិចេញវិញ្ញាបនប័ត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន  ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្វ័យវាយតំលៃ  និងឯកសារចាំបាច់មួយចំនួនទៀត  ដែលពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យនិងសូចនាករ ដូចបានពណ៌នាក្នុងសៀវភៅណែនាំ ។

២-របាយការណ៍ស្វ័យវាយតំលៃលើថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន  និងឯកសារពាក់ព័ន្ធដែលបានបញ្ជូនមកអគ្គលេខាធិការដ្ឋាន  គ.ទ.ក  នឹងត្រូវបានត្រួតពិនិត្យដោយនាយកដ្ឋានស្តង់ដារ  និងការទទួលស្គាល់គុណភាពអប់រំ ។

៣-ក្រោយពេលចុះវាយតំលៃក្រុមមន្ត្រីវាយតំលៃ និងមន្ត្រីជំនាញនឹងរៀបចំរបាយការណ៏ ស្វ័យវាយតំលៃដើម្បីដាក់ជូននាយកដ្ឋានស្តង់ដារ និងការទទួលស្គាល់គុណភាពអប់រំ ពិនិត្យ ។ នាយកដ្ឋាន ស្តង់ដារ និងការទទួលស្គាល់គុណភាពអប់រំបូកសរុបរបាយការណ៏ ហើយបញ្ជូនមកអគ្គលេខាធិការ នៃ គ.ទ.ក ពិនិត្យ និងផ្តល់យោបល់ ជូនទៅ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ពិនិត្យ និង សំរេចជាចុងក្រោយ ។

នៅឆ្នាំ២០០៦ គ.ទ.ក បានចាត់តាំងក្រុមមន្ត្រីវាយតម្លៃ ចុះវាយតម្លៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅតាមគ្រឹះស្ថានឧត្តមសិក្សាទាំងនៅរាជធានីភ្នំពេញនិងខេត្ត-ក្រុងនានា ចំនួន ៥៧ ដែលក្នុងនោះមានគ្រឹះស្ថានឧត្តមសិក្សាសាធារណៈទីតាំងគោលនិងសាខាចំនួន១៣គ្រឹះស្ថាន និងគ្រឹះស្ថានឧត្តមសិក្សាឯកជនមានចំនួន៤៤គ្រឹះស្ថាន ។

**ខ- ការពិនិត្យ និងផ្តល់ការយល់ព្រមលើកម្មវិធីសិក្សាដែលស្នើសុំថ្មី និងស្នើសុំការកែសំរួល**

- ផ្តល់ការយល់ព្រមលើកម្មសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានរបស់វិទ្យាស្ថានគ្រប់គ្រងនៃកម្ពុជា
- ផ្តល់ការយល់ព្រមលើកម្មសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានរបស់វិទ្យាស្ថាន ប៊ែលធីអន្តរជាតិ
- ផ្តល់ការយល់ព្រមលើការស្នើសុំការកែសំរួលកម្មវិធីសិក្សារបស់សាកលវិទ្យាល័យអន្តរជាតិ
-ផ្តល់ការយល់ព្រមលើកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន សកលវិទ្យាល័យវេទមហាឬសីមហាវិទ្យាល័យភាសាអង់គ្លេស
-ផ្តល់ការយល់ព្រមលើការស្នើសុំការកែសំរួលកម្មវិធីសិក្សារបស់សាកលវិទ្យាល័យមេគង្គ កម្ពុជា ។
-ផ្តល់ការយល់ព្រមលើកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានរបស់សាកលវិទ្យាល័យស្វាយ រៀង
-ផ្តល់ការយល់ព្រមលើកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានរបស់វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**គ. ការងារបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន**

-រៀបចំសិក្ខាសាលាដល់ស្រង់បទពិសោធន៍លើការអនុវត្តថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដែលប្រព្រឹត្តទៅនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ថ្ងៃទី ២៩ -៣០ ខែ វិច្ឆិកា ២០០៦ ។
-រៀបចំការប្រជុំណែនាំមន្ត្រីវាយតំលៃអំពីដំណើរការវាយតម្លៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន ។

**ឃ-ការងារដែលកំពុងបន្ត**

១. ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

- កំពុងពិនិត្យកែសំរួលសៀវភៅណែនាំថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសំរាប់ដាក់ឱ្យអនុវត្តឆ្នាំសិក្សា ២០០៦-២០០៧ ។
- រៀបចំការប្រជុំពិនិត្យពិភាក្សាលើសៀវភៅណែនាំមន្ត្រីវាយតំលៃ សំរាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននាសាលប្រជុំអគ្គលេខាធិការដ្ឋាន ។
- កំពុងពិនិត្យកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន វិទ្យាស្ថានសហព័ន្ធអឺរ៉ុប ។
- កំពុងពិនិត្យលើការស្នើសុំកែសំរួលកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានរបស់ វិទ្យាស្ថានវ៉ាន់ដា
- កំពុងពិនិត្យលើការស្នើសុំកែសម្រួលកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានរបស់សាកលវិទ្យាល័យកម្ពុជា ។
- កំពុងពិនិត្យកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ពុទ្ធិកសាកលវិទ្យាល័យព្រហ្មនុរាជ ។

- កំពុងពិនិត្យកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន សាកលវិទ្យាល័យអង្គរ ។
- កំពុងពិនិត្យកម្មសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន វិទ្យាស្ថានវិទ្យាគ្រប់គ្រងនិងអភិវឌ្ឍន៍ ។
- កំពុងពិនិត្យកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន សាកលវិទ្យាល័យ អ៊ីសវេស៍ ។
- កំពុងពិនិត្យកម្មសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង ។
- កំពុងពិនិត្យកម្មសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន សាកលវិទ្យាល័យវេស្ទើន ។
- កំពុងពិនិត្យកម្មសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន សាកលវិទ្យាល័យ សេដ្ឋកិច្ច និងនីតិសាស្ត្រ

២. ស្តង់ដារអប្បរមា

-បានសិក្សាបញ្ចប់ ដោយមានការពិគ្រោះយោបល់ជាមួយទីក្រឹក្សាបរទេសជាចុងក្រោយ ហើយ បច្ចុប្បន្ននេះ កំពុងពិនិត្យពិភាក្សាផ្ទៃក្នុងអគ្គលេខាធិការដ្ឋាន ។
- រៀបចំដាក់ស្តង់ដារអប្បរមាឱ្យមានការប្រជុំពិគ្រោះយោបល់ជាមួយគ្រឹះស្ថានឧត្តមសិក្សា ។
- រៀបចំបង្កើតសូចនាករលំអិតនៃស្តង់ដារនីមួយៗ ។
- រៀបចំបង្កើតទំរង់គំរូរបាយការណ៍ស្វ័យវាយតំលៃសំរាប់ស្តង់ដារអប្បរមា ។
- រៀបចំសៀវភៅណែនាំអំពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា (Institutional Accreditation Manual and Assessor Manual ) ។
- បកប្រែសៀវភៅណែនាំទាំងពីរជាភាសាអង់គ្លេស ។
- លើកសំណើសុំការយល់ព្រមឱ្យប្រើប្រាស់សៀវភៅទាំងពីរ ។

## ២-ការងារកិច្ចសហប្រតិបត្តិការនិងព័ត៌មាន

### ក-ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ

### ក.១-កិច្ចសហប្រតិបត្តិការជាមួយធនាគារពិភពលោក

ធនាគាពិភពលោកបានផ្តល់ជំនួយចំនួន ១លាន ដុល្លាអាមេរិកដល់ **គ.ទ.ក** ដើម្បីពង្រឹងសមត្ថភាព ទាំងខាង សំភារៈ ធនធានមនុស្ស និងធានាប្រសិទ្ធភាពនៃដំណើរការទទួលស្គាល់គុណភាពអប់រំសំរាប់រយៈពេល៣ឆ្នាំ ។ ជំនួយចំនួន១លាន ដុល្លាអាមេរិកនេះ ជាផ្នែកតូចមួយនៃគំរោង CESSP (Cambodian Education Sector Support Project) របស់ក្រសួងអប់រំ យុវជន និង កីឡា ដែលមានទឹកប្រាក់ចំនួន ៣០លានដុល្លា អាមេរិក ដែលក្នុងនោះមាន២០លានដុល្លាជាជំនួយឥតសំណង និង ៨លានដុល្លាជាឥណទានរបស់ធនាគារពិភពលោក ហើយ ២លានដុល្លាជាថិកាបដិភាគរបស់រាជរដ្ឋាភិបាល ។

### ក. ២-កិច្ចសហប្រតិបត្តិការជាមួយប្រទេស និង អង្គការអន្តរជាតិនានា

- អង្គការ APQN (Asia-Pacific Quality Network) បានអញ្ជើញតំណាងអគ្គលេខាធិការដ្ឋាន គ.ទ.ក មួយរូបទៅចូលរួម ទៅចូលរួមសិក្ខាសាលា ស្តីពី**ការវាយតំលៃគ្រឹះស្ថានឧត្តមសិក្សាពីខាងក្រៅ** (External Review for Higher Education) ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១២-១៣ ខែ មករា ឆ្នាំ ២០០៦ នៅទីក្រុង ហានណូយ ប្រទេស វៀតណាម ។

- អង្គការ APQN (Asia-Pacific Quality Network) បានអញ្ជើញតំណាងអគ្គលេខាធិការដ្ឋាន គ.ទ.ក មួយរូបទៅចូលរួមសិក្ខាសាលា ស្តីពីកិច្ចសហប្រតិបត្តិការធានាគុណភាពអប់រំក្នុងការផ្លាស់ប្តូរនៅក្នុងតំបន់ " Regional Mobility: Cooperation in Quality Assurance" ដែលប្រព្រឹត្តិទៅនៅថ្ងៃទី០២-០៤ ខែមីនា ឆ្នាំ ២០០៦ នៅទីក្រុងសៀងហៃ ប្រទេសចិន ។

-ស្ថានទូតសហរដ្ឋអាមេរិកប្រចាំទីក្រុងភ្នំពេញបានអញ្ជើញ តំណាងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ទៅចូលរួមកម្មវិធីភ្ញៀវអន្តរជាតិដើម្បីសិក្សាស្វែងយល់ អំពី **រដ្ឋបាលសាកលវិទ្យាល័យ** (The international visitor program on University Administration) ពីថ្ងៃទី ៦-២៧ ខែ មេសា ឆ្នាំ ២០០៦ ។

- ថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាន គ.ទ.ក ចំនួន០៤រូបបានទៅចូលរួមសិក្ខាសាលាស្តីពី និន្នាការពិភពលោកនិងទស្សនវិស័យលើការធានាគុណភាពអប់រំវិស្វកម្ម (Global Trend and Perspectives on the Quality Assurance Engineering Education) ដែលរៀបចំ Japan Accreditation Board for Engineering Education (JABEE នៅថ្ងៃទី ១៥-១៦ ខែ ធ្នូ ឆ្នាំ ២០០៦ នៅទីក្រុង Tokyo ប្រទេសជប៉ុន) ។

- សហប្រតិបត្តិការជាមួយអង្គការ និង ស្ថាប័នធានាគុណភាពអប់រំឧត្តមសិក្សាទាំងក្នុងតំបន់ និងអន្តរជាតិ ដូចជា APQN, JABEE and CHEA ។

**ខ-ការងារកិច្ចសហប្រតិបត្តិការជាតិ**

អគ្គលេខាធិការដ្ឋាន **គ.ទ.ក** បានធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធមួយចំនួនដូចខាងក្រោម:

-បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងការពារជាតិ និងសាកលវិទ្យាល័យអន្តរជាតិ ដើម្បីរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីលក្ខណៈវិនិច្ឆ័យបង្កើតគ្រឹះស្ថានឧត្តមសិក្សាដែលបណ្តុះបណ្តាលផ្នែកសុខាភិបាល ។

-បានសហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា និងសាកវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាក្នុងការរៀបចំវគ្គពិសេសបណ្តុះបណ្តាលថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ សម្រាប់មន្ត្រីរាជការវ័យចំណាស់ និងឥស្សរជន ។

-បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំបង្កើតគណៈកម្មាធិការពិនិត្យវាយតំលៃករិតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សា ។

**គ-ការងារពត៌មាន**

- រៀបចំទស្សនាវដ្តី " គុណភាពអប់រំ " របស់ គទក

-បានចងក្រងឯកសារសាកលវិទ្យាល័យបរទេសទៅតាមតំបន់នីមួយៗចំនួន ១ច្បាប់ ។

-បានតាមដានរាល់ការផ្សាយពត៌មានទាក់ទងនឹង **គ.ទ.ក** នៅតាមប្រព័ន្ធផ្សព្វផ្សាយពត៌មាន ។

-បានចងក្រងទិន្នន័យកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់គ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេស ។

- រៀបចំកែលំអ គេហទំព័រ គទក

- រៀបចំបណ្ណាល័យ គទក សម្រាប់ការសិក្សាស្រាវជ្រាវពីគុណភាពអប់រំ

-ចូលរួមពិនិត្យខ្លឹមសារ នៃការផ្សព្វផ្សាយព័ត៌មានរបស់ គ្រឹះស្ថាន ឧត្តមសិក្សា

-ស្រាវជ្រាវព័ត៌មាន ឬ ទិន្នន័យដែលពាក់ព័ន្ធនឹងគុណភាពអប់រំ តាម Newspapers and Internet

## ៣-ការងារកិច្ចការទូទៅ

**ក-ការងាររដ្ឋបាល**

-បានរៀបចំវិញ្ញាបនបត្រទទួលស្គាល់គុណភាពអប់រំលើ ដំណើរការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ២០០៥-២០០៦ និង បានទទួលថវិកាបង់វិភាគទានពីគ្រឹះស្ថានឧត្តមសិក្សា ចំនួន ៥៤។

-បានទទួលពាក្យ និង សំណុំឯកសាររបស់គ្រឹះស្ថានឧត្តមសិក្សាចំនួន៥៤ ដែលបានស្នើសុំឱ្យគ.ទ.ក ចុះវាយតម្លៃលើដំណើរការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឆ្នាំសិក្សា ២០០៥-២០០៦ ។

-បានរៀបចំលិខិតស្នាមមួយចំនួនទៅគ្រឹះស្ថានឧត្តមសិក្សា និង ស្ថាប័នដែលពាក់ព័ន្ធ។

-បានទទួលសម្ភារៈការិយាល័យពីគំរោងទ្រទ្រង់វិស័យអប់រំកម្ពុជា។

-បានធ្វើសំណើសុំថវិកាពីគំរោងទ្រទ្រង់វិស័យអប់រំកម្ពុជាសំរាប់ចុះវាយតម្លៃលើដំណើរ

-ការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឆ្នាំសិក្សា ២០០៥-២០០៦ នៅតាមបណ្តាខេត្តក្រុង។

-បញ្ជូន សេចក្តីជូនដំណឹងស្តីពីការអនុវត្តន៏កម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និង ការជ្រើសរើសមន្ត្រីវាយតំលៃគុណភាពអប់រំឧត្តមសិក្សាទៅតាមគ្រឹះស្ថានឧត្តមសិក្សានានា ។

-អញ្ជើញតំណាងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជនដើម្បីមកចូលរួមប្រជុំ។

-ធ្វើលិខិតស្នាមផ្សេងៗ ដែលពាក់ព័ន្ធនឹងការងាររបស់អគ្គលេខាធិការដ្ឋាន គ.ទ.ក ។

-បោះពុម្ពក្បាលលិខិត អល គ.ទ.ក ជាភាសាខ្មែរ និង ភាសាអង់គ្លេស ។

-បញ្ជូនសេចក្តីជូនដំណឹងស្តីពីការជ្រើសរើសមន្ត្រីវាយតំលៃគុណភាពអប់រំទៅតាមគ្រឹះស្ថានឧត្តមសិក្សា និង ក្រសួងស្ថាប័នរដ្ឋទាំងអស់ និងបានចុះផ្សព្វផ្សាយដំណឹងនេះនៅតាមទំព័រកាសែត ។

-បានទទួលពាក្យដាក់សុំបំរើការងារជាមន្ត្រីវាយតំលៃគុណភាពអប់រំ និងបានរៀបចំបញ្ជីឈ្មោះសំរាប់ធ្វើការសម្ភាសន៏ ។

-បានរៀបចំព្រាងអនុក្រឹត្យ ស្តីពី ការបង់វិភាគទានសេវារដ្ឋបាលសម្រាប់ដំណើរការវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា។

**ខ-អំពីកិច្ចប្រជុំ គ.ទ.ក និង កិច្ចប្រជុំអគ្គលេខាធិការដ្ឋាន**

**ខ.១- អំពីកិច្ចប្រជុំ គ.ទ.ក**

នៅថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០០៦ វេលាម៉ោងបួនរសៀល នៅសាលប្រជុំទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា(គ.ទ.ក) បានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។ អង្គប្រជុំបាន ពិភាក្សា និងអនុម័តផ្តល់ការទទួលស្គាល់គុណភាពអប់រំថ្នាក់ឆ្នាំសិក្សាមូលដ្ឋានដល់គ្រឹះស្ថានឧត្តមសិក្សា និង ពិភាក្សាបញ្ហាផ្សេងៗ។

**ខ.២- អំពី កិច្ចប្រជុំអគ្គលេខាធិការដ្ឋាន**

ដើម្បីជំរុញការអនុវត្តការងារអោយមានប្រសិទ្ធភាព និងទទួលបានជោគជ័យទៅតាមផែនការការងាររបស់ខ្លួន អគ្គលេខាធិការដ្ឋានបានប្រជុំផ្ទៃក្នុងរបស់ខ្លួន រួមមាន ប្រជុំសាមញ្ញ និង វិសាមញ្ញ ចំនួន ២៥ លើក នៅក្នុងឆ្នាំ ២០០៦។

-នៅថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៦ បានអញ្ជើញមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាចូលរួមប្រជុំពិភាក្សាប្តូរយោបល់លើការចុះវាយតម្លៃលើដំណើរការថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅតាមគ្រឹះស្ថានឧត្តមសិក្សាកន្លងមក ។

-នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៦ បានអញ្ជើញតំណាងគ្រឹះស្ថានឧត្តមសិក្សាដើម្បីចូលរួម

ប្រជុំស្តីពី ការណែនាំការចេញវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ២០០៥-២០០៦។

-នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៦ បានអញ្ជើញតំណាងគ្រឹះស្ថានឧត្តមសិក្សាចូលរួមប្រជុំស្តីពីការផ្តល់ការទទួលស្គាល់គុណភាពអប់រំលើដំណើរការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ២០០៥-២០០៦។

-នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៦ បានអញ្ជើញឯកឧត្តម សាកលវិទ្យាធិការ និង លោកនាយកគ្រឹះស្ថានឧត្តមសិក្សាចូលរួមប្រជុំស្តីពីបញ្ហាពាក់ព័ន្ធនឹងដំណើរការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងការបង់វិភាគទានជូន គ.ទ.ក ។

-នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ បានអញ្ជើញតំណាងអគ្គនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និង កីឡា ចូលរួមប្រជុំអំពីបញ្ហាសាកលវិទ្យាល័យវែនឡែន។

-នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៦ បានរៀបចំ និង អញ្ជើញតំណាងគ្រឹះស្ថានឧត្តមសិក្សាចូលរួមសិក្ខាសាលាស្តីពីការវាយតម្លៃ នៃការអនុវត្តន៍ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ២០០៥-២០០៦។

**គ-អំពីបុគ្គលិក**

នៅឆ្នាំ ២០០៦ អគ្គលេខាធិការដ្ឋានមានមន្ត្រី ចំនួន ២៤ រូប ។ មន្ត្រីជាប់កិច្ចសន្យាចំនួន ០៦រូបត្រូវបានបញ្ចូលទៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈក្រោមទីស្តីការគណៈរដ្ឋមន្ត្រី។

មន្ត្រីថ្នាក់អនុប្រធាននាយកដ្ឋានមួយរូបត្រូវបានផ្ទេរទៅបំរើការងារនៅនាយកដ្ឋានបុគ្គលិកនៃទីស្តីការគណៈរដ្ឋមន្ត្រី។

## II- **ទិសដៅការងារនាពេលខាងមុខ**

-ចុះវាយតំលៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅតាមគ្រឹះស្ថានឧត្តមសិក្សានានា ដើម្បីផ្តល់ការទទួលស្គាល់គុណភាពអប់រំ។

-ដើម្បីឱ្យមានការចូលរួមពីគ្រឹះស្ថានឧត្តមសិក្សាឱ្យកាន់តែសកម្មថែមទៀត គ.ទ.ក ត្រូវចុះណែនាំនិងធ្វើបទបង្ហាញពីការធានាគុណភាពអប់រំឧត្តមសិក្សា(QA) នៅតាមគ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេស ។

- តំរូវការអ្នកជំនាញការ ខ្មែរ ឬ បរទេស ។
- បន្តបណ្តុះបណ្តាលមន្ត្រីវាយតំលៃ ។
- កែលំអបទដ្ឋានថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយផ្សេងៗ។

-ក្រោមគំរោងធាគាពិភពលោក ត្រូវបញ្ជូនមន្ត្រីជំនាញចេញទៅចូលរួមវគ្គបណ្តុះបណ្តាលនៅតាមបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍ខាងការធានាគុណភាពទាំងក្នុងតំបន់ និងពិភពលោកដើម្បីដកស្រង់បទពិសោធន៍ខាងផ្នែកនេះ។

- រៀបចំស្តង់ដារអប្បរមារសំរាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-ចុះធ្វើបទបង្ហាញ អំពី សូចនាករនៃស្តង់ដារអប្បរមា និងការសរសេររបាយការណ៍ស្វ័យវាយតំលៃសំរាប់ការទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សា និងតាមគ្រឹះស្ថានឧត្តមសិក្សាតាមបណ្តា ខេត្តក្រុង។

-ចុះធ្វើបទបង្ហាញ អំពីសូចនាករនៃលក្ខណៈវិនិច្ឆ័យ និងការសរសេររបាយការណ៍ស្វ័យវាយតំលៃសំរាប់ការទទួលស្គាល់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន តាមគ្រឹះស្ថានឧត្តមសិក្សាតាមបណ្តា ខេត្តក្រុង។

- រៀបចំឱ្យមានក្រមសីលធម៌សំរាប់មន្ត្រីវាយតំលៃ និងត្រូវរៀបចំឱ្យមានការផ្តល់ព័ត៌មានពីគ្រឹះស្ថានឧត្តមសិក្សាលើដំណើរការនៃការចុះវាយតំលៃរបស់មន្ត្រីវាយតំលៃ ។

-រៀបចំសៀវភៅស្តីពីគោលនយោបាយ របស់ **គ.ទ.ក**

-បង្កើតគ្រោងការគុណវុឌ្ឍន៍សិក្សាសំរាប់ការអប់រំឧត្តមសិក្សា

-បន្តកិច្ចសហប្រតិបត្តិការនេះបន្តទៀត ជាមួយប្រទេស និង អង្គការអន្តរជាតិនានា ដើម្បីស្វែងរកជំនួយបច្ចេកទេស និង ហិរញ្ញវត្ថុ ។

-ត្រូវការអ្នកជំនាញការបរទេសដើម្បីរៀបចំបទដ្ឋានខាងលើ

- បន្តកិច្ចសហប្រតិបត្តិការ ជាមួយ ក្រសួង-ស្ថាប័នពាក់ព័ន្ធ នានា

- ធ្វើសំណើសុំប្រេងឥន្ធនៈសំរាប់ឆ្នាំ២០០៧ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ធ្វើសំណើថវិការដ្ឋទេយ្យសំរាប់ឆ្នាំ ២០០៧ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ជ្រើសរើសបុគ្គលិកដែលមានសញ្ញាប័ត្រខ្ពស់មួយចំនួនបន្ថែមទៀត

- បន្តអនុវត្តភារកិច្ចចាំបាច់មួយចំនួនទៀតរបស់អគ្គលេខាធិការដ្ឋាន **គ.ទ.ក** ។

## III-**សេចក្តីសន្និដ្ឋាន**

ដោយសារតែមានការគាំទ្រយ៉ាងខ្លាំងពីរាជរដ្ឋាភិបាល និងពីសំណាក់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងការខិតខំប្រែងរបស់ថ្នាក់ដឹកនាំនិងមន្ត្រីទាំងអស់របស់អគ្គលេខាធិការដ្ឋាន ក្នុងឆ្នាំ២០០៦កន្លងមក អគ្គលេខាធិការដ្ឋានបានបំពេញភារកិច្ចទៅតាមផែនការការងាររបស់ខ្លួនប្រកបដោយជោគជ័យ និងទទួលលទ្ធផលល្អ ទាំងការងារផ្ទៃក្នុង និង ការងារកិច្ចសហប្រតិបត្តិការជាតិ និង អន្តរជាតិ ។